**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៣ ១៤០នាក់ នៃរោងចក្រ សហគ្រាស ទាំង៥ នៃវិស័យកាត់ដេរ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលត្រូវបានការព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី១នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្រោយការបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញទន់ ក្នុងនោះចំនួន៖

- ១៥២ ០០០រៀល (៣៨ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ៤៥ថ្ងៃ
- ៣០៤ ០០០រៀល (៧៦ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៥១ថ្ងៃ ឡើងទៅ។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៥ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ អង្គារ ១៥កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០២០*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ ចំនួន ៥ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 1 | ក្រុមហ៊ុន ខ្វាន់ទុម អ៊ីកែវីល (ខេមបូឌា) លីមីធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន មហា ហ្គាម៉ិន ខូ អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អេលីតវីន (ខេមបូឌា) ឯ.ក | កណ្តាល |
| 4 | ក្រុមហ៊ុន វ៉ាយ អិម ជី ហ្គាមេន អេកសេស៊េរី | កណ្តាល |
| 5 | ក្រុមហ៊ុន ប្រ៊ីភីស៊ីស (ខេមបូឌា) ហ្គាមេន អិលធីឌី | កណ្តាល |